នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសង |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃ៣១ ខែមករា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jan-2014, 13:27
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

## សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រីAnta GUISSÉ

# សេចក្តីសន្និដ្ឋាន

១. ជាការឆ្លើយតបទៅនឹងកថាខណ្ឌទី៥ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ដែលបានបង្គាប់ថា "ការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរណាមួយស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០២ ត្រូវធ្វើឡើងត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤"[1] សហព្រះរាជសូមផ្តល់ការជូនដំណឹងថា សំណើរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ នៅតែរក្សានៅដដែលដូចមានចែងក្នុងកថាខណ្ឌទី៩ ដល់២០ នៃសេចក្តីសន្និដ្ឋានរបស់ខ្លួនចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ ដែលមានចំណងជើងថា "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការរួមជាមួយឧបសម្ព័ន្ធ ក"[2]។

២. ដូចដែលបានរៀបរាប់លម្អិតនៅក្នុងឯកសារដែលដាក់កាលពីថ្ងៃទី៥ ខែធ្នូ ២០១៣ ទីតាំងឧក្រិដ្ឋកម្ម ឬព្រឹត្តិការណ៍ជាក់លាក់ទាំងឡាយដែល សហព្រះរាជអាជ្ញាបានស្នើសុំឲ្យដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ០០២/០២ នោះគឺមាន៖(១) មន្ទីរសន្តិសុខស-២១ ដែលក្នុងនោះរួមទាំងជើងឯកផង។ (២) ការប្រព្រឹត្តិមកលើជនជាតិវៀតណាម (ដោយមិនរាប់បញ្ចូលនូវឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជានៅលើទឹកដីវៀតណាម) (៣) ការប្រព្រឹត្តិមកលើជនជាតិចាម (ដោយមិនរាប់បញ្ចូលមន្ទីរសន្តិសុខក្រូចឆ្មារ) (៤) សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលរាប់បញ្ចូលទាំងការធ្វើបាបលើពុទ្ធសាសនិកជន និងអាពាហ៍ពិពាហ៍ដោយបង្ខំផង (៥) ការដ្ឋានពលកម្មទំនប់ ១ មករា (៦) ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង (៧) មន្ទីរសន្តិសុខអូរកន្សែង និង (៨) មន្ទីរសន្តិសុខភ្នំក្រោល។

៣. សហព្រះរាជអាជ្ញាសូមលើកឡើងម្តងទៀតថា គេត្រូវតែកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ ដោយអនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលថា "សំណុំរឿង ០០២/០២ ត្រូវ

[1] **E301/5** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី: "ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ", ២៤ ធ្នូ ២០១៣។

[2] **E301/2** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការរួមជាមួយឧបសម្ព័ន្ធ ក", ៥ ធ្នូ ២០១៣, កថាខណ្ឌទី៩-២០, ២៧។

រួមបញ្ចូល ជាអប្បបរមា នូវបទចោទទាក់ទងនឹងមន្ទីរ ស-២១ ការដ្ឋានធ្វើការ សហករណ៍ និងអំពើប្រល័យពូជសាសន៍”[3]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |

[3] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌ ៧៦។